# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** 12.116/07 **គ.ជ.ប** ណែន

## សេចក្តីណែនាំ

## ស្តីពីការពិនិត្យផ្ទៀងផ្ទាត់សេចក្តីព្រាងបញ្ជីបោះឆ្នោត

## ជាមួយបញ្ជីបោះឆ្នោតដំបូងប្រចាំឆ្នាំ ២០០៧

**យោង :**
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ឆ្នាំ ២០០៨
- ប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ឆ្នាំ ២០០៨

### អគ្គលេខាធិការ

ណែនាំដល់អស់លោក លោកស្រីប្រធាន លខ/កប ឱ្យចាត់ចែងអនុវត្តការងារតាមខ្លឹមសារ ដូចខាងក្រោម ៖

**I**-បញ្ជូនសេចក្តីព្រាងបញ្ជីបោះឆ្នោតទៅឃុំ សង្កាត់ ពាក់ព័ន្ធដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយបញ្ជីបោះឆ្នោតដំបូង ។

**II**- ណែនាំដល់ក្រុមប្រឹក្សា និងស្មៀនឃុំ សង្កាត់ ពាក់ព័ន្ធ ឱ្យអនុវត្តការផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោត ដូចខាងក្រោម ៖

១- ស្មៀនឃុំ សង្កាត់ ត្រូវផ្ទៀងផ្ទាត់សេចក្តីព្រាងបញ្ជីបោះឆ្នោតដែលបានបញ្ជូនមក ជាមួយបញ្ជីបោះឆ្នោតដំបូង ដែលត្រូវយកចិត្តទុកដាក់ទៅលើចំណុចសំខាន់ៗ ដូចខាងក្រោម ៖

ក. ពិនិត្យលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត ។

ខ. ផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតនីមួយៗ

- បើបញ្ជីដែល គ.ជ.ប ផ្ញើទៅ មានចំនួនអ្នកបោះឆ្នោតលើស ត្រូវគូសបន្ទាត់ឆូតពីលើដើម្បីលុបឈ្មោះនោះចេញ
- បើបញ្ជីដែល គ.ជ.ប ផ្ញើទៅមានចំនួនអ្នកបោះឆ្នោតខ្វះ ត្រូវសរសេរឈ្មោះដែលបាត់នោះនៅផ្នែកខាងក្រោម ។

គ. ផ្ទៀងផ្ទាត់ទិន្នន័យពាក់ព័ន្ធ និងអក្ខរាវិរុទ្ធលើឈ្មោះប្រជាពលរដ្ឋតាមតួអក្សរនីមួយៗអោយបានត្រឹមត្រូវតាមបញ្ជីបោះឆ្នោតដំបូង ជៀសវាងច្រឡំព្យញ្ជនៈមួយចំនួនដែលមានទម្រង់ប្រហាក់ប្រហែលគ្នា ដូចជា ឈ្មោះ**ចាន** ទៅជា **ឆាន** ឬទៅជា **ធាន** និងឈ្មោះ **លាង** ទៅជា **ណាង** ។ល។

ឃ. ធ្វើការកែតម្រូវដោយប្រើប៊ិច ប្រសិនបើមានចំណុចខ្វះខាត ។

ង. ចុះហត្ថលេខានៅផ្នែកខាងក្រោម ព្រមទាំងបញ្ជូនទៅប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់ ពិនិត្យសម្រេច ។

២- ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវពិនិត្យផ្ទៀងផ្ទាត់នៅលើសេចក្តីព្រាងបញ្ជីបោះឆ្នោត រួចចុះហត្ថលេខា និងបោះត្រា ។

**III**- បន្ទាប់ពីផ្ទៀងផ្ទាត់បានត្រឹមត្រូវរួចហើយ ត្រូវបញ្ជូនបញ្ជីបោះឆ្នោតទាំងនេះ មក គ.ជ.ប យ៉ាងយូរបំផុតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2007 ដើម្បី គ.ជ.ប រៀបចំផ្តល់សុពលភាព និងបោះពុម្ពបញ្ជីបោះឆ្នោតផ្លូវការ ។

ទទួលបានសេចក្តីណែនាំនេះ សូមអស់លោក លោកស្រី ប្រធាន លខ/កប ក្រុមប្រឹក្សា/ស្មៀនឃុំ សង្កាត់ ពាក់ព័ន្ធយកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាព ។

ភ្នំពេញ ថ្ងៃទី 11 ខែ 12 ឆ្នាំ ២០០៧

**អគ្គលេខាធិការ**

**ទេព_នីថា**